# Living the Lotus
## Buddhism in Everyday Life

7
2024
VOL. 226











Rissho Kosei-kai of Phnom Penh





**Living the Lotus**
**Vol. 226 (July 2024)**

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin
*Living the Lotus* is published monthly by Rissho Kosei-kai International, Fumon Media Center, 2-7-1 Wada, Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិករីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

# ឆាកជីវិតរបស់យើងម្នាក់ៗនិង “ជីវិតអមតៈ”

ដោយព្រះគ្រូនីវ៉ាណុ នីជីកុ
ព្រះប្រធានរីហ្សូកូសេកៃ



## ឆាកជីវិតគឺជាការរត់បណ្ដាក់

ខ្ញុំព្រះករុណាអាត្មាភាពសូមណែនាំកាព្យឃ្លោងមួយដែលសរសេរដោយព្រះគ្រូខាងនិកាយលីនសៃគឺព្រះគ្រូម៉ាតស៊ីបារ៉ា ថៃដូដែលតែងតែបកស្រាយព្រះពុទ្ធសាសនាឱ្យពុទ្ធសាសនិកស្រួលយល់យ៉ាងទន់ភ្លន់នៅពេលដែលព្រះអង្គមានព្រះជន្ម៨០ព្រះវស្សា៖

“ម៉ែទាញដៃអាត្មាឡើងភ្នំ ឆ្លងស្ទឹង ជាង៨០ឆ្នាំទម្រាំនឹងមានថ្ងៃនេះ។”

នៅក្នុងបាឋកថាដែលព្រះអង្គសម្ដែងក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ព្រះគ្រូបានបន្ដកំណាព្យថ្លែងអំណរគុណនិងក្ដីស្រឡាញ់ចំពោះមាតាដោយស្មោះត្រង់បានបទថា៖

“-កូនអរគុណម៉ែ ដែលបានចិញ្ចឹមនិងពង្រស់កូនឱ្យកូនបានរស់រានមានជីវិតដល់ពេលនេះ។”

ខ្ញុំព្រះករុណាអាត្មាភាពយល់ថាដល់រដូវធ្វើបុណ្យបិណ្ឌម្ដងៗមនោសញ្ចេតនានឹកឃើញដល់មាតាបិតាដែលស្លាប់បាត់បង់ជីវិតទៅតែងតែឡើងជ្រាលជ្រៅជាងសព្វមួយដងនេះមិនមែនកើតមានឡើងតែចំពោះអាត្មាភាពម្នាក់ឯងដែលមានអាយុស្មើនឹងព្រះគ្រូនៅពេលដែលលោកតែងកាព្យនេះទេ។ម្យ៉ាងទៀតមានកំណាព្យមួយទៀតដែលព្រះគ្រូលោកបានបន្សល់ទុកក្នុងកម្រងពាក្យកាព្យរបស់លោកដែលបានទាក់ទាញចិត្តខ្ញុំព្រះករុណាអាត្មាភាពដែរ។

“ឆាកជីវិតមនុស្សគឺជាការរត់បណ្ដាក់ដែលគ្មានទីបញ្ចប់។ក្នុងឆាកជីវិតដែលជាការរត់បណ្ដាក់រាប់កោដិឆ្នាំបន្ដមកហើយ មនុស្សកើតហើយស្លាប់ ហើយក្នុងរយៈពេលនោះមនុស្សខំព្យាយាមរត់ ហើយហុចកូនដំបងដែលខ្លួនកាន់ទៅអ្នកបន្ទាប់ឱ្យរត់បន្ដពីខ្លួន។” (『ជីវិតព្រះធម្មទេសនារបស់ម៉ាតស៊ីបារ៉ាថៃដូ』 ការបោះពុម្ពផ្សាយរបស់គ្រឹះស្ថានកូសេ)

ដែលហៅថាជីវិត គឺតែងតែទទួលសេចក្ដីស្លាប់នៅពេលណាមួយ។យើងទាំងឡាយតែងតែគិតថាមរណភាពគឺជាទីបញ្ចប់នៃឆាកជីវិតក៏ប៉ុន្ដែព្រះគ្រូម៉ាតស៊ីបារ៉ាលោកសរសេរថាឆាកជីវិតគឺការរត់បណ្ដាក់ដែលគ្មានទីបញ្ចប់។

មួយល្បះដែលថែងថា“ទោះជាដល់ពេលដែលមរណភាពចូលមកដល់ក្ដីវេលានោះមិនមែនជាទីបញ្ចប់នៃជីវិតទេ” ផ្ដល់មកឱ្យខ្ញុំព្រះករុណាអាត្មាភាពនូវភាពកក់ក្ដៅនិងអារម្មណ៍

ស្រស់ស្រាយក្រៃលែង។ចម្ងាយនៃការរត់ក្ដី របៀបរត់ក្ដីនៃជីវិតនីមួយៗខុសគ្នាមែនពិតក៏ប៉ុន្តែអ្នករត់ប្រណាំងម្នាក់ៗខិតខំអស់ពីសមត្ថភាពនៅក្នុងកំណត់នៃលំហាមួយហើយដំបងនៃជីវិតបានត្រូវហុចបន្តទៅអ្នកម្នាក់ទៀតដែលបន្តរត់ពីខ្លួនពីម្នាក់ទៅម្នាក់រហូតជាអាលជ្ជីគ្មានឈប់ឈរ។

## រស់「ជីវិតអមតៈ」

លោកសាស្ត្រាចារ្យហៀវ៉ាសាវ៉ា ខូដែលជាសាកលវិទ្យាធិការសាកលវិទ្យាល័យក្យូតុ បានបង្ហាញពីទស្សនៈទៅលើជីវិតដែលបានប្រព្រឹត្តមករាប់កោដិឆ្នាំយ៉ាងក្បោះក្បាយថាៈ

ដែលហៅថាមរណភាពគឺការវិលត្រឡប់ទៅរកមហាធម្មជាតិនៃជីវិតដែលមហាធម្មជាតិបានផ្តល់មកឱ្យ ៗទៅជាចំណែកមួយនៃមហាធម្មជាតិដើម្បីចូលរួមក្នុងការកសាងមហាធម្មជាតិជាថ្មីឡើងវិញ។នេះមិនមែនវិលត្រឡប់ទៅរកសូន្យឬ មោឃៈទេគឺការចូលរួមកសាងមហាធម្មជាតិថ្មីមួយ។ (『តស់ថ្ងៃនេះក៏យើងសប្បាយនឹងរស់』 គ្រឹះស្ថានបោះពុម្ពជីជី) ។

ពីពាក្យសម្ដីខាងលើយើងមិនទទួលនូវភាពឯកោឬភាពសោកសង្រេងដោយសារតែការចូលមកដល់នៃមរណភាពឡើយ។ផ្ទុយទៅវិញ យើងមើលឃើញនូវរូបភាពដ៏ធំមួយនៃជីវិតរបស់យើងទាំងអស់គ្នាដែលយកមរណភាពជាព្រំប្រទល់ដែលបន្តអតីតកាលនិងអនាគតកាល ដូចជាមហាទន្លេដែលវិលត្រឡប់ទៅស្រុកដើមកំណើត និងវិលត្រឡប់ទៅមហាធម្មជាតិ។ គឺជាជីវិតដែលរស់ជាអមតៈបន្តរហូតមិនឈប់ឈរ។

មនុស្សជាច្រើនភ័យខ្លាចការចូលមកដល់នៃមរណភាព ហើយបារម្ភ។មានមនុស្សខ្លះទៀតមិនចង់គិតថាខ្លួនឯងនឹងរលុបបាត់ពីភពផែនដីនេះឡើយ។សូមគិតថាមូលហេតុដែលព្រះសម្មាសម្ពុទ្ធលោកខិតខំរិះរកសច្ចធម៌គឺលោកចង់ស្រោចស្រង់មនុស្សគ្រប់គ្នាឱ្យផុតពីទុក្ខដែលបណ្ដាលមកពីកើតចាស់ឈឺស្លាប់នេះឯង។ដូច្នេះយើងអាចនិយាយបានថាការចង់ចៀសវាងសេចក្ដីស្លាប់គឺជាមនោសញ្ចេតនាធម្មតា។ក៏ប៉ុន្តែព្រះសម្មាសម្ពុទ្ធជាចុងបញ្ចប់លោកបានបន្សល់ទុកឱ្យយើងនូវធម៌ដែលជាវិធីសាស្ត្រសម្រាប់ជម្នះលើសេចក្ដីទុក្ខនិងសេចក្ដីបារម្ភទាំងនោះរួមមានព្រះធម៌អនិច្ចំ ចតុអរិយសច្ចៈនិងមាគ៌ាត្រឹមត្រូវទាំង ៨ ដែលនរណាម្នាក់ក៏នឹងបានប្រោស និងការទទួលយកទុក្ខនិងកិច្ចប្រតិបត្តិដូចការប្រោសនាងបដាចារដែលបាត់បង់កូនដោយព្រះអង្គលើកយកគ្រាប់ល្ងមកធ្វើជាឧទាហរណ៍។នាងបដាចារបាននិយាយថាដោយសារជំនួបជាមួយនឹងព្រះសម្មាសម្ពុទ្ធនាងខ្ញុំម្ចាស់បានប្រតិបត្តិព្រះធម៌៨ដែលជាមាគ៌ាដ៏ថ្លៃថ្លាហើយបានដល់មាគ៌ានៃការមិនស្លាប់។នាងខ្ញុំម្ចាស់បានដល់នូវការត្រាស់ដឹងដ៏ស្ងប់ស្ងាត់ហើយបានឆ្លុះកញ្ចក់សច្ចៈធម៌។

នៅក្នុងសេចក្ដីសារភាពនេះយើងមានចំណាប់អារម្មណ៍ទៅលើពាក្យ“មិនស្លាប់” មួយ។នៅក្នុងគម្ពីរ“សុត្តបិដក” មានព្រះពុទ្ធដីការបស់ព្រះសម្មាសម្ពុទ្ធមួយឃ្លាថា “អ្នកដែលភ្ជួររាស់បេះដូងនឹងបានទទួលនូវផលអមតៈ” ។តើ “អមតៈ” នេះមានន័យថាម៉េច?ដើម្បីឱ្យយើងរាល់គ្នាដែលប្រឈមមុខនឹងសេចក្ដីស្លាប់នៅក្នុងការពិតអាចរស់នៅដោយស្ងប់ស្ងាត់គ្មានបារម្ភជារៀងរាល់ថ្ងៃ នៅលេខក្រោយខ្ញុំព្រះករុណាអាត្មាភាពនឹងនិយាយពី “អមតៈ” ឬ “មិនស្លាប់” នេះ។



“កូសេ” លេខខែ៧ឆ្នាំ២០២៤




# A Global Buddhist Movement




Information about local Dharma centers

facebook

X

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp